global witness

Lloyds Chambers, 1 Portsoken Street
London, E1 8BT
United Kingdom
Phone: +44 (0)207 4925820
Fax: +44 (0)207 4925821
Email: mail@globalwitness.org
www.globalwitness.org

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
វិមានសន្តិភាព
មហាវិថីសហព័ន្ធរុស្ស៊ី
ខណ្ឌ 7 មករា រាជធានីភ្នំពេញ

ថ្ងៃទី 2 ខែសីហា ឆ្នាំ2016

<u>លិខិតបើកចំហរ ជូនចំពោះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន</u>

សម្តេចនាយករដ្ឋមន្ត្រី ជាទីគោរព ៖

ក្នុងរយៈពេលជិតមួយខែដែលសកម្មជន និងអ្នកអត្ថាធិប្បាយនយោបាយ កែម ឡី ត្រូវ បានបាញ់សម្លាប់នៅកណ្តាលថ្ងៃ ក្នុងរាជធានីភ្នំពេញ មានរបាយការណ៍បង្ហាញថា មិត្តភក្តិ និងអ្នករួមការងាររបស់គាត់ រងការគំរាមកំហែង និងការបំភិតបំភ័យ ។ សកម្មជន ចំនួន ពីរូប គឺ ជុំ ហួរ និង ជុំ ហួត ត្រូវបាន គេរាយការណ៍ប្រាប់ថាបានជម្លៀសខ្លួនទៅប្រទេសថៃដើម្បីការពារជីវិតឱ្យផុតគ្រោះភ័យ ។

នេះជាភារកិច្ចរបស់រដ្ឋាភិបាល ក្នុងរបបប្រជាធិបតេយ្យ ដែលការពារ សិទ្ធិ និងសន្តិសុខរបស់ប្រជាពលរដ្ឋខ្លួន រួមទាំងអ្នករិះគន់ផងដែរ ។ ក្នុងនាមជាហត្ថលេខី លើសន្ធិសញ្ញាសិទ្ធិមនុស្សជាច្រើន រួមទាំងកិច្ចព្រមព្រៀងអន្តរជាតិ ស្តីពីសិទ្ធិជនស៊ីវិល និងសិទ្ធិនយោបាយផងដែរ យើងខ្ញុំ សូមអំពាវនាវឱ្យរដ្ឋាភិបាលរបស់សម្តេច ធ្វើការធានាលើ សុវត្ថិភាពរបស់បុគ្គលទាំងនេះ និងអ្នកដែលគាំទ្រពួកគេ ហើយគោរពសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់ពួកគេ ។

ឃាតកម្មសម្លាប់លោក កែម ឡី គឺជាព្រឹត្តិការណ៍ថ្មីបំផុត នៃបណ្តាអំពើហឹង្សានានាប្រឆាំង នឹងសមាជិកគណបក្សប្រឆាំង សកម្មជន និងអ្នកសារព័ត៌មាន ហើយកំពុងធ្វើឱ្យអាប់ឱនដល់ដំណើរការលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅកម្ពុជា ។ ដំណាក់កាលដំបូងនៃការស៊ើបអង្កេតលើ ឃាតកម្មលោក កែម ឡី មិនបានធ្វើអ្វីទាល់តែសោះដើម្បីកាត់បន្ថយការភ័យខ្លាចដែលថា ការស៊ើបអង្កេតនេះ នឹងត្រូវបរាជ័យដោយមិនអាចកំណត់រក ឬកាត់ទោសអ្នកដែលបញ្ជាលើបទឧក្រិដ្ឋបានដូចលើកមុនៗ ដែរ ។

រដ្ឋាភិបាលរបស់សម្តេច ត្រូវចាត់ឱ្យមាន ការស៊ើបអង្កេត ដោយហ្មត់ចត់ និង ឯករាជ្យ ជាបន្ទាន់ចំពោះករណីឃាតកម្មលោក កែម ឡី ។ ប្រជាពលរដ្ឋកម្ពុជា រាប់សិបម៉ឺននាក់ ដែលចូលរួម ដង្ហែរសពគាត់ រួមជាមួយការថ្កោលទោសជាអន្តរជាតិដែលបានធ្វើឡើង កាន់តែច្រើនឡើងលើឃាតកម្មនេះ សបញ្ជាក់យ៉ាងច្បាស់ថា គ្រប់ការស៊ើបអង្កេតឯករាជ្យដែលមានលក្ខណៈមិនពេញលេញ នឹងមិនទទួលបានការជឿទុកចិត្តនោះទេ ។

សូមសម្តេចទទួលនូវការគោរពរាប់អានពីខ្ញុំ ។

ផាទ្រិក អាឡេយ៍(Patrick Alley)
សហស្ថាបនិក&នាយក
អង្គការ Global Witness